CWEA

សមាគមសហគ្រិនស្ត្រីកម្ពុជា

CAMBODIA WOMEN ENTREPRENEURS ASSOCIATION

# លក្ខណៈសម្បត្តរបស់ក្រុមប្រឹក្សាភិបាល
# នៃសមាគមសហគ្រិនស្ត្រីកម្ពុជា (ស.ស.ស.ក.)

## I. គុណសម្បត្តិរបស់សមាជិកក្រុមប្រឹក្សាភិបាល ស.ស.ស.ក.

1. ត្រូវតែជាសហគ្រិនស្ត្រី ឬ ជាម្ចាស់អាជីវកម្មដែលជាស្ត្រី (ដោយមិនប្រកាន់សញ្ជាតិ) ដែលកំពុងប្រតិបត្តិការ អាជីវកម្មស្របច្បាប់ នៅ និង អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
2. ត្រូវមានទស្សនវិស័យ ឆន្ទៈ និងគោលជំហរច្បាស់លាស់ រឹងមាំ ទាក់ទងស្ត្រីក្នុងធុរកិច្ច ដើម្បីដឹកនាំ ស.ស.ស.ក. អោយមានភាពរីកចម្រើនរុងរឿងប្រកបដោយស្ថេរភាព ចីរភាព និង តម្លាភាព
3. ត្រូវគាំទ្រយ៉ាងសកម្ម និងផ្តល់ភាពអង់អាចដល់ស្ត្រីក្នុងធុរកិច្ច និងតួនាទីស្ត្រីក្នុងសហាគមន៍អាជីវកម្ម។

## II. តម្រូវការ

1. យល់ច្បាស់ ជឿជាក់ និងគាំទ្រ បេសកកម្ម ទស្សនវិស័យ និង តម្លៃស្នូលរបស់ ស.ស.ស.ក.
2. ត្រូវមានភាពជាអ្នកដឹកនាំ សមត្ថភាពក្នុងការចែករំលែកចំណេះដឹង បទពិសោធ និង សមត្ថភាពក្នុងការបណ្តុះបណ្តាល
3. ត្រូវមានជំហររឹងមាំក្នុងការការពារទឡ្ហីករណ៍របស់ខ្លួន មានសមត្ថភាពក្នុងការចូលរួមការពិភាក្សានានា បញ្ចេញគំនិតយោបល់ ដើម្បីការពារផលប្រយោជន៍របស់ស្ត្រី មានសមត្ថភាព ត្រួតពិនិត្យឡើងវិញនូវគោលការ និងផែនការនានា របស់សមាគម
4. មានសមត្ថភាពក្នុងការ វិភាគ វាយតម្លៃ និងមាន បទពិសោធ ក្នុង ការ វិភាគបញ្ហាអភិវឌ្ឍន៍ ដែលនាំទៅរកបុព្វហេតុល្អៗសម្រាប់ ស.ស.ស.ក.
5. បេក្ខជនមិនត្រូវជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងអង្គការ ឬអង្គភាពណាមួយផ្សេងទៀត ដែលអាចនឹងមានបញ្ហាទំនាស់ផលប្រយោជន៍ចំពោះ ស.ស.ស.ក.

6. មានជំនាញក្នុងការគ្រប់គ្រង និង ដោះស្រាយបញ្ហា
7. មានជំនាញទំនាក់ទំនងអន្តរបុគ្គល និង ទំនាក់ទំនងជាសាធារណៈ ល្អ
8. ប្តេជ្ញាចិត្ត ចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំ និងសកម្មភាព ក៏ដូចជាកម្មវិធីនានារបស់ ស.ស.ស.ក.
9. មានឆន្ទៈលះបង់ពេលវេលានិងថាមពល សម្រាប់ ស.ស.ស.ក. ជាពិសេស
10. មានគំនិតជឿនលឿន សុចរិតភាព និងបើកចិត្តទូលាយ
11. មានឆន្ទៈទទួលយកគំនិតយោបល់ផ្សេងៗទាក់ទងនឹងបញ្ហាអភិវឌ្ឍ ទោះបីជាគំនិតទាំងនោះ ស្ថិតក្នុងស្ថានភាពចម្រូងចម្រាស់យ៉ាងណាក៏ដោយ
12. មានបទពិសោធធ្វើការជាក្រុម មិនប្រកាន់បក្សពួក និងមិនលម្អៀង

## III. បទពិសោធ និង ជំនាញបន្ថែម

1. មានបទពិសោធធ្លាប់ជាសមាជិកក្រុមប្រឹក្សាភិបាល
2. មានបទពិសោធក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងធុរកិច្ច ការគ្រប់គ្រងធនធានមនុស្ស ការរៀបចំផែនការកម្មវិធី ការសរសេរគម្រោងផែនការយុទ្ធសាស្ត្រ និងការរៃអង្គាសមូលនិធិ
3. មានបទពិសោធក្នុងការគិតស៊ីជម្រៅ
4. អាចសរសេរ អាន ស្តាប់ និង និយាយទាំងភាសាខ្មែរនិងអង់គ្លេស
5. ចេះប្រើប្រាស់ កំព្យូទ័រ ប្រព័ន្ធទំនាក់ទំនងបណ្តាញសង្គម និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម (ដូចជា Facebook Telegram ជាដើម)
6. ចេះប្រើប្រាស់កម្មវិធីរដ្ឋបាលក្នុងកុំព្យូទ័រ ដូចជា Microsoft Words, Microsoft Excel, Microsoft PowerPoint, ... ។ល។

**__________ចប់__________**